**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

# សារជូនពរ

**សូមគោរពជូន**

**សម្តេច កត្តាព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន**

**ប្រធានកាកបាទក្រហមកម្ពុជា**

**សម្តេចកត្តាព្រឹទ្ធបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់ !**

ក្នុងឱកាសដ៏មហានក្ខត្តឫក្សឧត្តុង្គឧត្តម នៃពិធីប្រារព្ធខួបកំណើតគម្រប់៦២ ឈានចូល៦៣ ឆ្នាំ របស់ **សម្តេចកត្តាព្រឹទ្ធបណ្ឌិត** តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទ ក្នុងនាមខ្លួនខ្ញុំនិងភរិយាខ្ញុំ សូមបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក សូមព្រះមេត្តាប្រោសប្រទានប្រសិទ្ធពរជ័យ សិរីសួស្តី មហាប្រសើរជូន **សម្តេចកត្តាព្រឹទ្ធបណ្ឌិត** សូមទទួលបាននូវបញ្ញាឈ្លាសវៃ សុខភាពល្អបរិបូរណ៍ ដើម្បីបំពេញសកម្មភាពមនុស្សធម៌ដ៏ឧត្តុង្គឧត្តម និងដឹកនាំកាកបាទក្រហមកម្ពុជាឲ្យទទួលបានជោគជ័យថ្មីៗនិងធំៗថែមទៀត រួមចំណែកជាមួយរាជរដ្ឋាភិបាល ដោះស្រាយរាល់ទុក្ខលំបាករបស់ប្រជាពលរដ្ឋ។

យើងខ្ញុំទាំងអស់គ្នាជាកងយោធពលខេមរភូមិន្ទ សូមចូលរួមអបអរសាទរគាំទ្រយ៉ាងក្លៀវក្លា និងកក់ក្តៅបំផុតចំពោះជោគជ័យនិងសមិទ្ធផលធំៗជាច្រើន ដែល**សម្តេចកត្តាព្រឹទ្ធបណ្ឌិត** សម្រេចបានក្នុងរយៈពេលកន្លងមក ក្នុងសកម្មភាពមនុស្សធម៌ជួយរំលែក និងដោះស្រាយរាល់ទុក្ខលំបាករបស់ប្រជាពលរដ្ឋដែលទទួលរងគ្រោះមហន្តរាយផ្សេងៗ ទុរគតជន ស្ត្រីមេម៉ាយ កូនកំព្រា ជនកើតជម្ងឺអេដស៍ និងផ្ទុកមេរោគអេដស៍។ ជាពិសេសពេលប្រជាពលរដ្ឋជួបនឹងគ្រោះធម្មជាតិម្តងៗ **សម្តេចកត្តាព្រឹទ្ធបណ្ឌិត** តែងតែយកចិត្តទុកដាក់ដោះស្រាយ និងសង្គ្រោះបានទាន់ពេលវេលា ធ្វើអោយប្រជាពលរដ្ឋមានជំនឿនិងទំនុកចិត្តលើ **សម្តេចកត្តាព្រឹទ្ធបណ្ឌិត** ដែលវិស័យមនុស្សធម៌ត្រូវបានលើកស្ទួយ កិត្យានុភាព កិត្តិយស និងកិត្តិស័ព្ទ របស់ព្រះរាជាណាចក្រកម្ពុជា កាន់តែខ្ពស់ត្រដែតល្បីរន្ទឺលើឆាកអន្តរជាតិ។

សូម **សម្តេចកត្តាព្រឹទ្ធបណ្ឌិត** ឧត្តមភរិយាសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា **បុត្រាបុត្រី** និង**ចៅប្រុសចៅស្រី**ជាទីស្រលាញ់ ជួបតែសុភមង្គល វិបុលសុខគ្រប់ប្រការ និងប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចកត្តាព្រឹទ្ធបណ្ឌិតប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា**ជាទីគោរពដ៏ខ្ពង់ខ្ពស់ មេត្តាទទួលនូវគារវភក្តីភាពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ ២០១៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ បាញ់**

វិថីហ្សកឌីមីត្រូវ ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖០២៣ ៨៨៣ ២៧៨៖ General@mod.gov.comUSER